# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦៩៦ អនក្រ.បក

10.06.11

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរសក្តិ និងតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- យោងអនុក្រឹត្យលេខ ៥១៥ អនក្រ.តត ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១១ ស្តីពីការកែសម្រួលចំនួនគណៈអភិបាលខេត្ត
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានដំឡើងឋានន្តរសក្តិ និងតែងតាំងមន្ត្រីរាជការចំនួន ០២រូប ជា**អភិបាលរង** នៃគណៈអភិបាលខេត្តក្រចេះ ដូចមានរាយនាមខាងក្រោម :

១-លោក **ហ៊ឿ ស៊ីយ៉េម** ពីឋានន្តរសក្តិអនុមន្ត្រី ថ្នាក់លេខ ៧ ទៅជាឋានន្តរសក្តិវរមន្ត្រី ថ្នាក់លេខ ៨ និងតែងតាំងជាអភិបាលរងខេត្តក្រចេះ ជំនួសលោក **ធុន គ្រី** ដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍។

២-លោកស្រី **ចិន សុភី** ពីឋានន្តរសក្តិ គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ៨ ទៅជាឋានន្តរសក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៩ នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម ក្រសួងអប់រំ យុវជន និងកីឡា និងតែងតាំងជាអភិបាលរងខេត្តក្រចេះ ជំនួសលោកស្រី **សា ចាន់ហ៊ាង** ដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍។

**មាត្រា ២** : ត្រូវបានតែងតាំងលោក **សរ ចំរុង** ឋានន្តរសក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៦ ជា**អភិបាលរង** នៃគណៈអភិបាលខេត្តក្រចេះ ។

**មាត្រា ៣** : ក្នុងរយៈពេលមកបំពេញភារកិច្ចក្នុងមុខតំណែងថ្មីខាងលើនេះ លោកស្រី **មិន សុភី** ត្រូវដាក់ពាក្យស្នើសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

**មាត្រា ៤** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ និងមាត្រា២ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ